# សម្រាប់ក្មេងៗ





## នៅក្នុងមួយជួរមានបី

លេងល្បែងនេះជាមួយមិត្តភក្តិម្នាក់ ! សូមផ្លាស់វេនគ្នា សរសេរ X ឬ O នៅក្នុងចន្លោះរហូតដល់នរណាម្នាក់មានអក្សរបីក្នុងជួរតែមួយ ។

« ខ្ញុំបានឃើញការនិមិត្ត ខ្ញុំដឹងថាខ្ញុំបានឃើញការនិមិត្ត ហើយខ្ញុំដឹងថាព្រះទ្រង់ក៏ដឹងថាខ្ញុំបានឃើញការនិមិត្ត ហើយខ្ញុំពុំអាចបដិសេធរឿងនេះបានឡើយ » ។

យ៉ូសែប ស៊្មីធ—ប្រវត្តិ ១:២៥

## ល្បែងសមត្ថភាពនៅក្នុងខែនេះ

សូមនិយាយជាមួយមនុស្សបីនាក់ដែលជាធម្មតាប្អូនមិនដែលនិយាយជាមួយ ។ សូមសរសេរឈ្មោះរបស់ពួកគេនៅទីនេះ ៖

## គូបមិត្តភាព

១. សូមកាត់គំរូនេះចេញ ។

២. បត់គំរូនេះតាមបន្ទាត់ទាំងនេះ ហើយបិតការនៅខាងចុងតាមកន្លែងរបស់វា ដើម្បីធ្វើជាគូប ។

៣. រមៀលគូបដើម្បីទទួលបានគំនិតអំពីអ្វីដែលត្រូវធ្វើជាមួយមិត្តភក្តិ ។ ( សូមចាំថា ៖ សមាជិកគ្រួសារក៏អាចជាមិត្តភក្តិបានដែរ ! )

ធ្វើនំចំណី ! ( សាកល្បងធ្វើស្រូវសាឡីទុកមួយយប់ នៅលើទំព័រ ៣២ ) ។



ការបម្រើដល់នរណាម្នាក់ ។ ប្រសិនបើអាច សូមធ្វើវាដោយសម្ងាត់ ។

សូមសរសេរគំនិតរបស់ប្អូនៗផ្ទាល់ !

បង្កើតល្បែងមួយដើម្បីលេងនៅខាងក្រៅ ។

គូររូបគ្នាទៅវិញទៅមក ។ កុំបង្ហាញវា រហូតទាល់តែប្អូនគូររួច !

រាយបញ្ជីនូវចំណុចប្រាំយ៉ាងដែលប្អូនចូលចិត្តអំពីគ្នា ។




## ល្បែងព្រៃដែលមានច្រកខ្វាត់ខ្វែង

សូមប្អូនស្វែងរកផ្លូវតាមព្រៃនេះដើម្បីទៅដល់ផ្ទះរបស់គ្រួសារ ស៊្មីធ ។



## ពាក្យពេចន៍មកពីប្អូនៗ



ខ្ញុំដឹងថា ព្រះគម្ពីរមរមនពិត ហើយយ៉ូសែប ស៊្មីធ គឺជាព្យាការីរបស់ព្រះ ។ នៅពេលខ្ញុំអធិស្ឋាន ខ្ញុំមានអារម្មណ៍ល្អនៅក្នុងចិត្ត ។

ឌើក ប៊ី អាយុ ៨ ឆ្នាំ រដ្ឋណាវ៉ាដា ស.រ.អា.



បន្ទប់ដែលខ្ញុំចូលចិត្តនៅឯព្រះវិហារបរិសុទ្ធគឺបន្ទប់ផ្សារភ្ជាប់ ។ ខ្ញុំដឹងថាថ្ងៃណាមួយខ្ញុំនឹងរៀបអាពាហ៍ពិពាហ៍ ហើយផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធសម្រាប់ភាពអស់កល្បជានិច្ច ។ ខ្ញុំចូលចិត្តទៅព្រះវិហារបរិសុទ្ធណាស់ ។

អ៊ីសាបែល អ័រ. អាយុ ១៧ ឆ្នាំ ស៊ីអែរ៉ា ប្រទេសប្រេស៊ីល